# ប្រភពនៃព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ

**Mores & Customs Commission**

ប្រភពនៃព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែជំនឿរបស់ខ្មែរ ក្នុងទំនៀមព្រះរាជពិធីប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ អាងដល់ប្រភពនានា ដូចពណ៌នាដោយសង្ខេបខាងមុខ ៖

## ប្រភពនៃព្រះរាជពិធីប្រណាំងទូក

1.ក) សៀវភៅ «ជយវរ្ម័នទី ៧» របស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ មានចែងថា ៖

«នៅសម័យអង្គរ នាគ្រិស្តសតវត្សទី ១២ ក្រុងកម្ពុជាមានសេចក្តីសុខក្សេមក្សាន្ត រុងរឿងណាស់ ដោយព្រះបាទជ័យវរ្ម័នទី ៧ ស្តេចចេញធ្វើសង្គ្រាមជើងទឹកបង្ក្រាបពួកចាម ដោយកងទ័ពទូក ជាចម្បាំងដោះក្រុងកម្ពុជាឲ្យរួចផុតស្រឡះចេញពីខ្មាំងសត្រូវ ( គ។ស. ១១៧៧-១១៨១)។ រឿងចម្បាំងគ្រានេះ មានឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន នឹងបន្ទាយឆ្មារ» ។

ក្នុងចម្លាក់នោះ ឃើញមានកងទ័ពទូកជាច្រើនមហិមា ដែលមានព្រះបរមឆាយាល័ក្ខណ៍នៃព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់ប្រថាប់ឈរលើព្រះទីនាំងនាវាចម្បាំង ដោយទ្រង់ធ្នូនឹងដំបងយ៉ាងសម្បើម ក្នុងចំណោមកងទ័ពទូកទាំងឡាយ ។

ខ) ឯកសារ «ល្បែងប្រណាំងទូក» របស់ក្រុមជំនុំទំនៀមទម្លាប់លេខ ១៩.០០៩ និពន្ធដោយលោក ថាច់-ប៉ែន ហៅ ប៉ាង អាចារ្យនៅពុទ្ធសាសនបណ្ឌិត្យរង ខែត្រឃ្លាំង កម្ពុជាក្រោម មានចែងថា :

«សម័យលង្វែក ( ព។ស. ២០៧១ គ.ស. ១៥២៨ ) ព្រះបាទអង្គចន្ទទី ១ ទ្រង់តាំងពញាតាត ងារជាស្និទ្ធភូបាល ជាស្តេចត្រាញ់នៅកម្ពុជាក្រោម ស្រុកបាសាក់ ។ ស្តេចត្រាញ់នេះបានចាត់របៀបរៀបចំការពារស្រុក មានរបៀបដូចរៀបរាប់តទៅនេះ ៖

ទាហានជើងទឹក ចែកជា ៣ ក្រុម៖

ក្រុមទី ១ ហៅទ័ពស្រួច ហាត់ច្បាំងនឹងទូកដែលមានជំនាងដូចទូកប្រណាំងយើងសព្វថ្ងៃ។

ក្រុមទី ២ ហៅទ័ពជំនួយ ហាត់ច្បាំងនឹងទូកចែវពីរជួរ ដែលមានជំនាងដូចទូកចែវប្រណាំង យើងសព្វថ្ងៃ ។

ក្រុមទី ៣ ហៅទ័ពបាសាក់ គឺទុកធំមានដំបូលមានចែវមានក្ដោង ដែលមានជំនាងដូចទូក បាសាក់ ហៅទុកប៉ុកចាយ តែរាងស្តួចវែង មានដំបូលតែមួយកាត់ខាងមុខ ឥតជញ្ជាំង ។ល។ ជាទូកដាក់ស្បៀងអាហារ សម្រាប់កងទ័ព ។ល។

របៀបបង្ហាត់ច្បាំង (តាមទំនៀមស្តេចត្រាញ់នៅកម្ពុជាក្រោម) ស្រេចលើមន្ត្រីទាំង ៤ ទិស ដែលឋិតនៅក្នុងឱវាទលោកស្និទ្ធភូបាល (ស្តេចត្រាញ់) គ្រប់ចំពូក ដែលបញ្ញត្តិច្បាប់ សម្រាប់ស្រុក ។ល។ កំណត់ថ្ងៃពេញបូណ៌មី ខែកត្តិក រដូវអកអំបុកនោះ, មន្ត្រីទាំង ៤ ទិស ត្រូវកេណ្ឌទាហានទាំងជើងគោកទាំងជើងទឹក ទៅប្រជុំនៅបន្ទាយស្តេចត្រាញ់ប្រឡងឫទ្ធិ គ្នា (សមយុទ្ធ) ១ ថ្ងៃ ១ យប់រាល់ឆ្នាំ ។

ចំណែកទាហានជើងទឹកឲ្យទៅប្រឡងឫទ្ធិឯទន្លេពាមកន្តោ ក្នុងខែត្រឃ្លាំង ដ្បិតកន្លែងនោះ ជាទីប្រជុំផ្លូវទឹកគ្រប់ខែត្រ នឹងទៅមកបានដោយស្រួល ។

តាមសៀវភៅ នឹងឯកសារ ជាប្រភពទាំង ២ ខាងលើនេះ អាចឲ្យសន្និដ្ឋានថា ប្រទេស កម្ពុជាសម័យបុរាណជាប្រទេសមានកងទ័ពជើងទឹកយ៉ាងខ្លាំងពូកែ នឹងមានពិធីហ្វឹកហ្វឺន ពិធីសមយុទ្ធកងទ័ពនេះ ជាប្រពៃណី រៀងរាល់ឆ្នាំ ហើយអាចសន្និដ្ឋានទៀតថា ដែល ប្រទេសកម្ពុជា សម័យបច្ចុប្បន្នធ្វើព្រះរាជពិធីអុំទូកនេះ គឺជាប់ពូជតមកអំពីព្រះរាជពិធីសម យុទ្ធ ដែលត្រូវនឹងភាសាបារាំងថា ម៉ាណឺវ្រ៍ ( Manœuvre ) នៃកងទ័ពទូក ក្នុងសម័យបុរាណ នោះឯង ។

## ប្រភពនៃព្រះរាជពិធីបណ្តែតប្រទីប

ក) គម្ពីរទាឋាវង្ស ភាសាបាលី មានចែងថា ព្រះចង្កូមកែវទាំង ៤ នៃព្រះសម្មាសម្ពុទ្ធជាបរម គ្រូប្រតិស្ឋាននៅទីទាំង ៥ គឺ

**ទី ១ - នៅត្រៃត្រឹង្សសួគ៌**

**ទី ២ - នៅនាគពិភព**

**ទី ៣ - នៅស្រុកគន្ធា**

**ទី ៤ - នៅទន្តបុរៈ កលិង្គរដ្ឋ ។**

ខ) ភាណវារៈបាលី ត្រង់ពុទ្ធនមក្ការគាថា មានចែងថា ព្រះបាទនៃព្រះសម្មាសម្ពុទ្ធជាបរមគ្រូប្រតិស្ឋាននៅទីទាំង ៥ គឺ

**ទី ១ - នៅសុវណ្ណមាលិកបពិត**

**ទី ២ - នៅសុវណ្ណបពិត**

**ទី ៣ - នៅសុមនកូដបពិត**

**ទី ៤ - នៅយោនកបុរី**

**ទី ៥ - នៅស្ទឹងនម្មទា ។**

គ) ពាក្យសរសើរព្រះបាទទាំងបាលី (យស្សបាទេ) ទាំងសម្រាយក៏មានចែងថា ព្រះបាទនៃព្រះសម្មាសម្ពុទ្ធបរមគ្រូប្រតិស្ឋាននៅទីទាំង ៥ ដូចក្នុងភាណវារៈដែរ ។

ដោយហេតុ មានគម្ពីរដីកាជាប្រភពដូច្នេះ បានពុទ្ធបរិស័ទខេមរជាតិតែងធ្វើពិធីបណ្តែតប្រទីប នៅយប់ពេញបូណ៌មី ខែអស្សុជ, ព្រះរាជាតែងទ្រង់ធ្វើព្រះរាជពិធីបណ្តែតប្រទីប នៅយប់ ១៤ - ១៥ កើតនឹង ១ រោច ខែកត្តិក បូជាចំពោះព្រះចង្កូមកែវនៅនាគពិភព ព្រះពុទ្ធបាទនៅស្ទឹងនម្មទា នឹងនៅទីឯទៀត ៗ ដូចពោលហើយ ដោយជឿថាជាការកុសល នឹងជាព្រះរាជកុសលដ៏ធំដែលបានផលយ៉ាងប្រសើរដើម្បីសេចក្តីសុខចំរើន-រុងរឿង ដល់ខ្លួន ដល់ព្រះអង្គ នឹងដល់ប្រទេសជាតិ ។

## ប្រភពនៃព្រះរាជពិធីសំពះព្រះខែ

## គម្ពីរបរមត្ថទីបនី អដ្ឋកថាចរិយាបិដក ភាសាបាលីមានចែងថា ៖

ក្នុងដើមភទ្ទកប្បនេះ ព្រះបរមពោធិសត្វនៃយើង ទ្រង់ឧប្បត្តិជាសសបណ្ឌិត (ទន្សាយ)។ នៅថ្ងៃពេញបូណ៌មី ១ ទ្រង់អធិដ្ឋានឧបោសថសីលហើយទ្រង់ឧទ្ទិសព្រះមំសៈព្រះអង្គជាទានបរមត្ថបារមី ដើម្បីបំពេញព្រះពោធិសម្ភារឲ្យបានត្រាស់ជាព្រះពុទ្ធ ។ ព្រះឥន្ទទ្រង់ជ្រាបទ្រង់ក្រឡាព្រះអង្គជាព្រាហ្មណ៍ចាស់ មកសុំព្រះមំសៈសសបណ្ឌិតជាអាហារ

។ ព្រះពោធិសត្វឲ្យឥន្ទព្រាហ្មណ៍បង្កាត់ភ្លើង ដើម្បីដុតព្រះអង្គលោក ។ កាលឥន្ទព្រាហ្មណ៍បង្កាត់ភ្លើងឆេះឡើង ព្រះពោធិសត្វលោតចូលភ្លើងនោះ ភ្លើងពុំឆេះ ឥន្ទព្រាហ្មណ៍ស្ទុះទៅពរព្រះពោធិសត្វឡើងទៅដល់មណ្ឌលព្រះចន្ទ ហើយទ្រង់យកម្នាងសិលាគូររូបទន្សាយអធិដ្ឋានឲ្យនៅជាប់រហូតដល់ទីបំផុតកប្ប ។ ដោយអានុភាពទានបរមត្ថបារមីនៃព្រះពោធិសត្វផង សេចក្តីអធិដ្ឋានរបស់ព្រះឥន្ទផង រូបទន្សាយក៏ឃើញប្រាកដក្នុងចន្ទមណ្ឌលដរាបដល់សព្វថ្ងៃ ។

ដោយជឿតាមរឿងនេះហើយ បានជានៅវេលាយប់នៃថ្ងៃពេញបូណ៌មី ខែកត្តិករៀងរាល់ឆ្នាំ ខ្មែរយើងតែងយកនំចំណីមានអំបុក នឹងចេកជាដើមមកបូជាព្រះចន្ទហៅថា «ពិធីអកអំបុក ឬហៅថា ពិធីសំពះព្រះខែ» សូម្បីព្រះរាជាក៏ទ្រង់សព្វព្រះរាជហឫទ័យធ្វើព្រះរាជពិធីនេះដែរ ដូចបានពណ៌នារួចសព្វគ្រប់មកហើយ ។

## ព្រះរាជក្រិត្យក្រមទសភរិយា

Mores & Customs Commission

## ព្រះរាជក្រិត្យ
## ក្រមទសភរិយា
## ក្នុងរជ្ជកាលព្រះបាទសម្តេច ព្រះជ័យ ចេស្តា ( ចៅពញាសួរ ) គ.ស. ១៦៩៣
## ឃ្លួង និពន្ធ មន្ត្រី ញ៉ុក ថែមរួបរួម

## ពាក្យផ្តើម

ព្រះរាជក្រិត្យ ក្រមទសភរិយានេះកើតឡើងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យ ចេស្តា (ចៅពញាសួរ)ក្នុងឆ្នាំជាមួយនឹងក្រមពលទេព នឹងក្រមដទៃៗទៀតជាច្រើន ខុសគ្នាតែថ្ងៃ - ខែ គឺក្រមទសភរិយានេះ គេបានរៀបរៀងឬរួបរួមចម្លង នៅថ្ងៃអាទិត្យខែបុស្សឆ្នាំ មមែ ។ ឯក្រមពលទេព គេបានរៀបរៀងឬស្រង់ចម្លង នៅថ្ងៃចន្ទ ៣ រោច ខែកត្តិក ឆ្នាំ មមែ ក្នុងកម្លងមហាសករាជ ១៦១៥ ដូចគ្នា ។ឯសេចក្តីសារស័ព្ទក្រៅអំពីនេះ យើងបានពោលរួចមកហើយក្នុងក្រមពលទេពឯណោះ។

ពាក្យថា<<ក្រមទសភរិយា>>ប្រែថា<<ច្បាប់សម្រាប់ភរិយា ១០ ជំពូក>>បានដល់ភរិយា

ដូចម្តេចខ្លះច្បាប់ដើមមិនបានពោលទុកដោយច្បាស់លាស់ឡើយ មាននិយាយតែពីច្បាប់លក់ពិន័យប្រុស - ស្រី ប្តីប្រពន្ធ - សហាយស្មន់អន្ធករ - អាពុកម្តាយដូចជាលក់ពិន័យប្តីប្រពន្ធដែលបានគ្នាហើយលះលែងគ្នាវិញ -លក់ពិន័យប្រុសស្រីដែលសហាយគ្នា ហើយលែងលះគ្នាវិញ -លក់ពិន័យខ្ញុំនាំជំរត់កូនក្រមុំគេ - លក់ពិន័យអ្នកផងនាំជំរត់ប្រពន្ធគេ -លក់ពិន័យក្រមុំកម្លោះសហាយគ្នា លក់ពិន័យអាពុកម្តាយខាងប្រុសនឹងកូនប្រុស អំពីដំណើរកូនក្រមុំគេរត់មកនៅជាមួយនឹងកូនប្រុសរបស់ខ្លួនលក់ពិន័យអ្នកជាទៅសហាយនឹងខ្ញុំគេ លក់ពិន័យអ្នកដាក់ស្នេហ៍កូនក្រមុំគេលក់ពិន័យកូនប្រុសដែលទៅសហាយនឹងកូនក្រមុំគេ បានហើយលះលែងចោលលក់ពិន័យខ្ញុំគេនឹងខ្ញុំគេបានគ្នាហើយលះលែគ្នា ។ល។ ដូច្នេះជាដើមមិនមានរៀបរាប់ចេញឈ្មោះទសភរិយាសោះឡើយ ។ តាមទំនងនេះនាំឲ្យយើងយល់ថាតាមច្បាប់ដើមជាន់ដើមនោះ មិនមានធ្វើទោសដាក់គុក ឃុំខាំងមានកំណត់ ខែ -ឆ្នាំ នឹងបង្ខំ ឲ្យធ្វើការដូចសព្វថ្ងៃនេះទេ, វៀរលែងតែមានទោសជាឧក្រិដ្ឋ ដូចជាសម្លាប់គេដោយអាឃាដព្យាបាទជាដើមទើបត្រូវសម្លាប់តែម្តង ។ក្រៅអំពីនេះច្រើនតែធ្វើទោសដាក់ខ្នោះច្រកឃ្នាងនឹងវាយផ្ចាលបណ្តើរអាក្រោស ឬលក់ពិន័យតិចច្រើនតាមទោសានុទោស ដូចពោលមកហើយ។

ឯសំដីពាក្យពេចន៍ ក្នុងក្រមទសភរិយានេះ មានពាក្យក្រៗជាច្រើនអន្លើ ។ការចម្លងចេញមកនេះ គង់មានភ្លាត់ភ្លាំងមិនខានទេដ្បិតច្បាប់សាស្ត្រាស្លឹករឹតនោះមានវិបត្តិតួអក្ខរនឹងសេចក្តីជាច្រើនអន្លើដោយការចារចម្លងវេះរុះមកជាច្រើន

# ធម្មវិភាវិនី

Tripitika Commission


# ធម្មវិភាវិនី



ព្រះគ្រូសុវណ្ណញាណ **សូរ - ហាយ** ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង


## ប្រែតាមអត្ថនិងវិគ្គហៈរបស់ធម្មៈ

ពាក្យថាធម្មៈឬធម៌ព្រះសម្ពុទ្ធទ្រង់សំដែងសំដៅយកសេចក្ដីច្រើនយ៉ាងដែលធ្លាប់មានប្រាកដមកក្នុងគម្ពីរព្រះសូត្រព្រះវិន័យ នឹងព្រះអភិធម្មដោយច្រើន ពាក្យនេះហាក់ដូចជាសម្រាប់ប្រើសាធារណៈក្នុងទីផ្សេង ៗ ស្រេចហើយតែនឹងសមរម្យទៅតាមដំណើរសេចក្ដីដូចតទៅនេះ៖

**១ - ធម្មៈ** ប្រែថា « សភាវៈគឺសេចក្ដីពិត ឬថាចិត្តនឹងចេតសិកខាងកុសល, អកុសលនឹងអព្យាកតៈ » ដូចបទថាៈ កុសលា ធម្មោអកុសលា ធម្មា អព្យាកតា ធម្មា ។

**២ - ធម្មៈ** ប្រែថា « ប្រាជ្ញា » ដូចបទថាៈ សច្ចំ ធម្មោធិតិ នាកោ, សច្ចៈ ធម្មៈ ធិតិចាគៈ ( នេះជាឃរាវាសធម៌ ) ពាក្យថាធម្មៈ ក្នុងទីនេះ ជាឈ្មោះប្រាជ្ញា ។

**៣ - ធម្មៈ** ប្រែថា « ប្រាជ្ញា » ដូចបទថាៈ ធម្មោ ហវេ រក្ខតិ ធម្មចារី បុណ្យហ្នឹងឯងរមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ។

**៤ - ធម្មៈ** ប្រែថា « បញ្ញត្តិ ឬលំនាំភាសាគឺច្បាប់ដែរគេតាំងទុកនឹងលំនាំសំឡេង » ដូចបទថាៈ បញ្ញត្តិធម្មា និរុត្តិធម្មា ធម៌គឺបញ្ញត្តិ ធម៌គឺលំនាំភាសា ។

**៥ - ធម្មៈ** ប្រែថា « អាបត្តិ » ដូចបទថាៈ ចត្តារោ ងារាជិកា ធម្មា អាបត្តិបារាជិក ៤ ។

**៦ - ធម្មៈ** ប្រែថា « បរិយត្តិគឺការសិក្សា » ដូចបទថាៈ ឥធ ភិក្ខវេ ធម្មំ បរិយោបុណាតិ សុត្តំ គេយ្យំ ។ ល ។ ម្នាលភិក្ខុទាំងឡាយភិក្ខុក្នុងសាសនានេះតែងរៀននូវបរិយត្តិគឺសុត្ត គេយ្យ ។ល ។

**៧ - ធម្មៈ** ប្រែថា « ទេសនា » ដូចបទថាៈ ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ទេសនាចំពោះអ្នកទាំងឡាយ ។

**៨ - ធម្មៈ** ប្រែថា « និស្សត្តិនិជ្ជីវៈ គឺសភាវៈ មិនមែនជាសត្វ មិនមែនជាជីវិត » ដូចបទថាៈ តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ សភាវៈដែលមិនមែនជាសត្វជាបុគ្គល មិនមែនជាជីវិត រមែងមានក្នុងសម័យនោះេង ។

**៩ - ធម្មៈ** ប្រែថា « ប្រក្រតី, ធម្មតា » ដូចបទថាៈ អនិច្ចា វត សង្ខារា ឧប្បទវយធម្មិនោ ឱហ្ន៎សង្ខារទាំងឡាយមិនទៀងមានការកើតឡើងនឹងសូន្យទៅជាប្រក្រតី ឬជាធម្មតា ។

**១០ - ធម្មៈ** ប្រែថា « វិការៈគឺរបស់ប្រែប្រួល » ដូចបទថាៈ វយធម្មា សង្ខារា សង្ខារទាំងឡាយ មានការសាបសូន្យជាគ្រឿងប្រែប្រួល ។

**១១ - ធម្មៈ** ប្រែថា «គុណឬពរ » ដូចបទថាៈ ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ, ចត្តារោ ធម្មា វឌ្ឍន្តិ សភាវៈពីរយ៉ាងគឺគុណ ១ ទោស ១ ឲ្យផលមិនស្របគ្នាទេ, ពរ ៤ ប្រការរមែងចំរើន ។

**១២ - ធម្មៈ** ប្រែថា « ការប្រព្រឹត្តិមានសណ្តាប់ធ្នាប់ល្អ ឬឫកពា » ដូចបទថាៈ សីលវា កល្យាណធម្មោ បុគ្គលមានសីលមានសណ្តាប់ធ្នាប់ល្អ ។ សោតាបន្នោ អវិនិបាតធម្មោ សោតាបន្នបុគ្គលមានសណ្តាប់ធ្នាប់មិនធ្លាក់ចុះ ។ ពាលា ធម្មា បណ្ឌិតា ធម្មា ឫកពាជារបស់ជនពាល ជារបស់បណ្ឌិត ។

**១៣ - ធម្មៈ** ប្រែថា « សមាធិ » ដូចបទថាៈ ភាវិតធម្មោ កតសមណធម្មោ មានសមាធិចំរើនហើយ មានសមាធិបរិកម្មស្រេចហើយ ។

**១៤ - ធម្ម:** ប្រែថា « បច្ចុប្បន្ន » ដូចបទថា: ធម្មដ្ឋិតតា ធម្មនិយាមតា ស្ថិតនៅឬកំណត់នៅក្នុងបច្ចុប្បន្ន ។ ទិដ្ឋធម្មិកោ អត្ថោ ប្រយោជន៍បច្ចុប្បន្ន ។

**១៥ - ធម្ម:** ប្រែថា « ហេតុ ឬប្រវេណី » ដូចបទថា: ធម្មប្បដិសម្ភិទា ធម្មញ្ញូតា បែកធ្លាយប្រាជ្ញាក្នុងហេតុ ដឹងច្បាស់ហេតុ ។ ឯសំ ធម្មោ សនន្តនោ ប្រវេណីនេះ ជារបស់មានមកក្នុងកាលមុន ។

**១៦ - ធម្ម:** ប្រែថា « សាសនា » ថា « សេចក្តីពិត » ដូចបទថា: ស្វាក្ខាតោ ធម្មោ សាសនាមានលំអបទដើមឬពីរោះបទដើម ។ ញេយ្យធម្មោ ញាតធម្មោ សេចក្តីពិតដែលតថាគតគប្បីដឹង សេចក្តីពិតដែលតថាគតដឹងហើយ ។ ធម្មានុធម្មប្បដិបន្នោ បុគ្គលប្រតិបត្តិតាមសេចក្តីពិតសមគួរដល់សេចក្តីពិត ។

**១៧ - ធម្ម:** ប្រែថា « **បរមត្ថសច្ច** » ថា « **មគ្គផល - និព្វាន** » ដូចបទថា: ទិដ្ឋធម្មោ បត្តធម្មោ បានឃើញបរមត្ថសច្ច បានលុះបរមត្ថសច្ច ។ ភណិតោ ខោ ធម្មោ មគ្គផល និព្វានតថាគតបានហើយ ។ ឧទាហរណ៍ ដែលសំដែងមកនេះជាសេចក្តីរួបរួមអត្ថរបស់ពាក្យថាធម្ម:ប៉ុណ្ណោះ ។

លំដាប់ពីនេះនឹងពោលអំពីវិគ្គហ: របស់ធម្ម តទៅទៀត ធម្មស័ព្ទនេះមានវិគ្គហ: ច្រើនយ៉ាងតែក្នុងទីនេះ នឹងស្រង់យកត្រឹម ៥ យ៉ាង:

**១ - ចតូសុ អបាយេសុ សំសារេ សត្តេ អបតមានេ ធារេតីតិ ធម្មោ** សភាពគឺសេចក្តីពិតឯណា រមែងទ្រទ្រង់នូវសត្វទាំងឡាយ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំង ៤ ឬក្នុងសំសារវដ្តសភាពនោះឈ្មោះថាធម៌ ។

**២ - សលក្ខណំ ធារេតីតិ ធម្មោ** សភាពឯណារមែងទ្រទ្រង់ទុកនូវលក្ខណ:របស់ខ្លួនគឺកុសលទាំង ៤ មានកាមាវចរកុសលជាដើម សភាពនោះឈ្មោះថាធម៌ ។

**៣ - បាបកេ អកុសលេ ធម្មេ ធុនាតីតិ ធម្មោ** សភាពឯណារមែងកំចាត់នូវអកុសលធម៌ដ៏លាមកចេញ ( ចាកខន្ធសន្តាន ) សភាពនោះឈ្មោះថាធម៌ ។

**៤ - សោតាបន្នាទីហិ អរិយេហិ ធារិយតីតិ ធម្មោ** សភាពឯណាដែលព្រះអរិយទាំងឡាយ មានព្រះសោតាបន្នបុគ្គលជាដើម តែងទ្រទ្រង់ទុក ( ចាំទុកក្នុងសន្តាន ) សភាពនោះឈ្មោះថាធម៌ ។

**៥ - យថានុសិដ្ឋំ បដិបជ្ជមានេ ចតូសុ អបាយេសុ អបតមានេ សត្តេ ធារេតីតិ ធម្មោ** សភាពឯណាទ្រទ្រង់ធ្វើនូវពួកសត្វដែលប្រតិបត្តិសមគួរដល់ពាក្យប្រៀនប្រដៅ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំង ៤ សភាពនោះឈ្មោះថាធមិ ។

**អត្ថនឹងវិគ្គហៈ** របស់ធម្មៈ ដូចពោលមកនេះជាសេចក្តីជ្រាលជ្រៅទៅតាមបែបហួសវិស័យសោតវិញ្ញាណរបស់អ្នកដែលមិនបានរៀន បែបផែនប្រែបាលី តែទុកជាយ៉ាងណាក៏គង់យល់សេចក្តីខ្លះពុំខាន ។ ពាក្យថាធម្មៈឬធមិមួយម៉ាត់នេះ បើទុកជាមិនមានបទគុណស័ព្ទ គឺកុសលឬអកុសលនៅជិតខាង គង់យើងសង្កេតយល់បានតាមដំណើរសេចក្តី ។ ធម្មស័ព្ទនេះកម្រនឹងនិយាយឲ្យច្បាស់ ប្រែស្រាយឲ្យចំមកជាពាក្យខ្មែរយើងបាន ដំណើរនេះជាវិស័យរបស់អ្នករៀនវិធីប្រែបាលីទើបអាចនឹងយល់បានដោយងាយ ប៉ុន្តែអ្នកដែលមិនបានរៀនរបៀបប្រែបាលីក៏គង់មានន័យក្នុងផ្ទៃសេចក្តីនោះ ៗ បើកឱកាសឲ្យយល់បានដូចយល់ថានេះជាភាវេតព្វធមិ ( ធមិគួរចំរើន ) នេះជាបហាតព្វធមិ ( ធមិគួរលះបង់ ) តែប៉ុណ្ណេះក៏អាចប្រព្រឹត្តប្រតិបត្តិតាមសាសនាធមិបាន ឬធមិដែលមានមកក្នុងពួកផ្សេង ៗ យើងអាចសន្និដ្ឋានបានឥតភ័ន្តច្រឡំថា នេះជាធមិដ៏ល្អ នេះជាធមិដ៏លាមកដូច្នេះជាដើម ។

សេចក្តីរបស់ធម្មៈ ដែលមានក្នុងអត្ថនឹងវិគ្គហៈ ដូចពោលមកនេះសំដៅយកវត្តចរិយាដែលគួរប្រព្រឹត្តបានទាំងផ្លូវលោកផ្លូវធមិ ឬសេចក្តីល្អដែលជាច្បាប់ម្យ៉ាង សម្រាប់បន្ថយកំឡាំងសេចក្តីអាក្រក់របស់ពួកមនុស្ស ដើម្បីលើកកំឡាំងសេចក្តីល្អឲ្យមានបរិបូណ៌ នឹងបានឈានទៅរកសេចក្តីចំរើនឲ្យមានដំឡៃ មានបែបផែនសណ្តាប់ធ្នាប់ល្អប្លែកអំពីពួកសត្វតិរច្ឆាន ព្រោះថាការបរិភោគក្តី ដេកក្តី ភិតភ័យក្តី រួមសំវាសនឹងមេថុនក្តី ទាំង ៤ យ៉ាងនេះមានស្មើគ្នា ទាំងមនុស្សទាំងសត្វតិរច្ឆានប៉ុន្មាន ធមិទុកជាក្រិត្យក្រមសម្រាប់ប្រព្រឹត្តឲ្យសមស័ក្តិជាមនុស្ស ឬថាធមិនេះជាសញ្ញាប័ត្រសម្រាប់មនុស្សក៏បាន ព្រោះថាមនុស្សយើងត្រូវតែដំកល់ខ្លួននៅក្នុងសីលធមិណាមួយ ទុកជាគោលដ៏សំខាន់សម្រាប់ត្រកូលរបស់ខ្លួនបើមិនច្រើនក៏តិច ដែលហៅថាត្រកូលមានធមិដើម្បីជាគម្រាប់ដល់បុត្តធីតាតរៀងទៅកាលបើប្រាសចាកសីលធមិហើយមុខជានឹងរសាត់អណ្តែតទៅ ប្រទះប៉ះទង្គិចនឹងសេចក្តីទុក្ខលំបាក ដូចចកនឹងសំឡីដែលរសាត់អណ្តែតទៅតាមខ្យល់ ឬដូចរថយន្តនឹងនាវាដែលគ្មានចង្កូតគ្មានគ្រឿងទប់ មនុស្សដែលស្ថិតនៅក្នុងសីលធមិខ្ជាប់ខ្ជួននោះដូចរថយន្តនឹងនាវាដែលមានចង្កូត មានយុថ្កាសម្រាប់ទប់ ។

ពិតណាស់ ព្រះធមិដែលព្រះដ៏មានព្រះភាគបានសំដែងទុកហើយនោះជាច្បាប់ដ៏ល្អវិសេស សម្រាប់តម្រូវដល់ប្រជាជនជាតិមនុស្សគ្រប់ជាន់ បើកឱកាសឲ្យប្រព្រឹត្តប្រតិបត្តិជឿកាន់ ដើម្បីឲ្យមានសណ្តាប់ធ្នាប់ល្អឈមមុខត្រង់ទៅរកសេចក្តីសុខក្សេមក្សាន្តចៀសចាកគ្រោះថ្នាក់ ទុក្ខភ័យតាំងអំពីលោកនេះ រហូតដល់ខាងមុខ ។

## អំពីប្រវត្តិនឹងកិត្តិគុណរបស់ធម្មៈក្នុងពុទ្ធសាសនា៖

ធម្មៈគឺសេចក្តីពិតតែងចាប់កំណើតនៅក្នុងលោកជាធម្មតា ស្ថិតនៅជាចន្លោះនៃសេចក្តីវិនាស ធម្មតាវត្ថុអ្វី ៗ ទាំងអស់ក្នុងលោក មានប្រាក់មាសជាដើមដែលបុគ្គលតាក់តែងសិទ្ធស្ងួនធ្វើឡើង រមែងមានរូបប្រែប្រួលទៅផ្សេង ៗ តាមកាលសម័យដែលនិយមរាប់អាន ជួនកាលវត្ថុដែលមិនមែនជាប្រាក់មាសសុទ្ធទេ តែគេក្រឡៃធ្វើដោយក្លែងក្លាយឲ្យមានព័ណ៌ដូចប្រាក់មាសសុទ្ធក៏បាន ប៉ុន្តែរបស់ក្រឡៃនោះមិនយូរប៉ុន្មាននឹងប្រាកដដល់ភ្នែកអ្នកផងដែលអាចដឹងបាន ។ របស់នោះរមែងត្រឡប់ទៅជារបស់ថោកទាបឥតថ្លៃ នាំឲ្យខូចសេចក្តីប្រាថ្នារបស់អ្នកត្រូវការទូទៅ ក្នុងទីបំផុតរបស់ដែលបន្លំនោះប្រែទៅជាវត្ថុប្រើប្រាសពុំកើត សេចក្តីនេះយ៉ាងណាមិញ ក្បួនតម្រាច្បាប់ទម្លាប់ ក្នុងលិទ្ធិណាមួយ ដែលគេហៅថាធម៌ ដោយសេចក្តីសន្មតិរបស់គេដែលតាក់តែងឡើងដោយឧបាយមិនសមហេតុផល គឺថាដំណើរមិនពិត, ក្បួនច្បាប់ទាំងនោះ គង់ត្រូវអ្នកផងដែលមានប្រាជ្ញាល្អ យល់ទាស់ឬចាប់សេចក្តីខុសបាន ថាជាលទ្ធិមិនពិត បើជាមិនមានអ្នកណាចាប់ថ្នាក់បានភ្លាម ៗ ក៏គង់គេដឹងបាន ឬគេរាងចាលក្នុងកាលដែលឲ្យផលមិនស័ក្តិសិទ្ធិ លទ្ធិនោះក៏ទៅជារបស់រៀវរោយ សាបរលាប លែងមានអ្នកណាចុះចូលត្រូវការប្រតិបត្តិជឿកាន់ក៏យ៉ាងនោះដែរ ចំណែកខាងធម្មៈ គឺសេចក្តីពិតជាសភាពមានអាយុជីវិតរស់នៅក្នុងលោក មិនចេះរៀវរោយថយចុះដូច្នេះឡើយ ។

ស្វាក្ខាធម៌ ដែលព្រះសម្មាសម្ពុទ្ធរបស់យើង ទ្រង់បានត្រាស់ដឹងឡើងហើយ ទ្រង់ប្រកាសប្រដៅប្រជាជនក្នុងលោក កាលដើមដំបូង មិនសូវមានមនុស្សជ្រះថ្លាជឿកាន់ច្រើនប៉ុន្មាន លុះដល់កាលខាងក្រោយមក ទើបពួកទេវតានឹងមនុស្សបានដឹងឮសុះសាយច្រើនគ្នាស្ញើចសរសើរ ថា ឱហ្ន៎នេះជាធម៌ពិត ប្រព្រឹត្តទៅតាមសេចក្តីសុខក្សេមក្សាន្ត រួចនាំគ្នាប្រតិបត្តិកាន់តាម រហូតបានមគ្គផលនិព្វានតាមនិស្ស័យវាសនា យ៉ាងសក្តិសិទ្ធិដូចទឹកសម្រាប់លត់ភ្លើង ។ ធម្មៈ គឺសេចក្តីពិត នៃអាយុជីវិតដ៏មាំមួន ជារបស់មិនចេះចាស់មិនចេះស្លាប់ អាចរស់នៅទាំងមានដំឡៃអង្វែងតទៅមិនចេះចុះថ្លៃឡើយ សេចក្តីនេះគប្បីសន្និដ្ឋានបានដោយងាយ ដូចយ៉ាងព្រះធម៌របស់ព្រះសម្ពុទ្ធនៃយើងទាំងឡាយ ដែលព្រះអង្គសំដែងឡើងតាមពិត មិនវិបរីតខុសចាកសេចក្តីពិត បើយើងគិតតាំងអំពីឆ្នាំដែលព្រះអង្គបរិនិព្វានមកដល់ឥឡូវនេះបាន ២៤៨៩ ឆ្នាំហើយ ទោះបីយូរអង្វែងមកប៉ុណ្ណោះ ព្រះធម៌ក៏នៅថ្មី

ទៀងទាត់ដដែលដូចប្រក្រតីឥតមានចាស់គ្រាំគ្រា ប្រែប្រួល ខូចដំឡៃយ៉ាងណា ៗ ឡើយ សមដូចពុទ្ធភាសិតថាៈ

**ជីរន្តិ វេ រាជរថា សុចិត្តា អថោ សរីរម្បិ ជរំ ឧបេតិ**

**សតញ្ច ធម្មោ ន ជរំ ឧបេតិ សន្តោ ហវេ សព្ភិ បវេទយន្តិ**

សេចក្តីថា រាជរថទាំងឡាយ ដែលនាយជាងរចនាល្អហើយ រមែងចាស់គ្រាំគ្រាទៅពុំបាន មិនត្រឹមតែរថទាំងឡាយប៉ុណ្ណោះឡើយ ទោះទាំងសរីរៈរាងកាយ ( របស់សត្វទាំងឡាយ ) ក៏គង់ដល់នូវសេចក្តីចាស់គ្រាំគ្រាដូច្នោះដែរ មានតែធម៌របស់ពួកសម្បុរសទើបមិនដល់នូវសេចក្តីចាស់គ្រាំគ្រា ពួកសប្បុរសតែងចរចារជាមួយនឹងសប្បុរសផងគ្នា យ៉ាងនេះឯង ។ ពុទ្ធភាសិតដូចពោលមកនេះជាគ្រឿងអាងដើម្បីបញ្ជាក់ពាក្យថាធម៌ឲ្យឃើញពិត ថាជាសភាពមិនចេះចាស់គ្រាំគ្រា កាលបើមិនមានសេចក្តីចាស់ទេ សេចក្តីឈឺចាប់ក៏មិនមានកាលបើមិនមានសេចក្តីឈឺចាប់ទេ សេចក្តីស្លាប់ក៏មិនមាន ។ ពាក្យថាធម្មៈដែលអធិប្បាយមកនេះសំដៅយកសេចក្តីពិត ដែលសំដែងអំពីសេចក្តីល្អអាក្រក់ ជាសភាពឥតរូប មានតែនាម ។ ដែលចាប់កំណើតនៅក្នុងលោកសម្រាប់ដឹងបានដោយបញ្ញាចក្ខុប៉ុណ្ណោះ ឥតមាននរណាស្រាវជ្រាវរកប្រវត្តិឲ្យឃើញថាធម៌នេះចាប់កំណើតពីកាលណា ។ បានឡើយ ដូចភ្លើងនឹងខ្យល់ដែលគេមិនអាចដឹងដើមកំណើតបានដូច្នោះដែរ គឺជាធម្មជាតិតែងកើតមាននៅក្នុងលោកជាធម្មតា ។

សេចក្តីខាងលើនេះ ល្មមយល់បានថា អំពើល្អអាក្រក់ជារបស់បិតបេររស់នៅពាសពេញលោក ទាំងមគ្គផលនិព្វាន ក៏មាននៅប្រាកដមិនត្រូវវិនាសបាត់បង់ចាកលោកដោយអន្តរាយណាមួយ សូម្បីលោកធាតុទាំងមូលត្រូវភ្លើងឆេះ អំពើនឹងមគ្គផលនិព្វានអាចតាំងនៅដដែល ទោះបីនរណាក៏លុបលាងចេញពុំបាន ចំណែកខាងពាក្យរចៃករចាកថា ធម៌ថ្មី ធម៌ចាស់ នោះនឹងទន្ទ្រានចូលមកកាត់កំផែងគឺសេចក្តីពិតមិនបានឡើយ ។ បុណ្យគឺអំពើល្អ បាបគឺអំពើអាក្រក់គុណគឺសេចក្តីចំរើន ទោសគឺសេចក្តីវិនាស ទាំង ៤ យ៉ាងនេះជាដើមឈ្មោះថាប្រវត្តិគឺដំណឹងឬកំណើតរបស់ធម៌ ដែលជាសេចក្តីពិតមាននៅប្រចាំលោកសូម្បីក្នុងកាលកប្បខាំងកំបាំងបាត់ស្ងាត់ គឺកាលដែលមិនមានព្រះពុទ្ធត្រាស់ឡើង ឬមិនមានអ្នកប្រាជ្ញក៏ដោយក៏គង់បុណ្យ បាប គុណ ទោស បិតថេរតាំងនៅជាប្រក្រតីឥតមានសាបរលាបរលត់បាត់ទេ តាំងប្រជាជនក្នុងលោកក៏មិនដែលពុទ្ធនិយាយថា ឥឡូវនេះបុណ្យ បាប គុណទោស គាស់គ្រាំគ្រាណាស់ ឈឺដុនដាបណាស់ ឬថា ស្លាប់បាត់ទៅហើយ ដូច្នេះឡើយ ពាក្យដែលគេនិយាយរចៃករចាកជា ធម៌ថ្មី ធម៌ចាស់នោះត្រឡប់ទៅជាឥតប្រយោជន៍ទទេ ។ បើបុគ្គលប្រុសស្រីឯក្នុងលោកមានកាយវាចាចិត្ត ប្រព្រឹត្តល្អត្រូវតាមសីលធម៌ មាន

ព្រហ្មវិហារផ្សាយទៅក្នុងពួកសត្វ មានកតញ្ញូកតវេទី ចំពោះលោកអ្នកមានគុណគឺមាតាបិតាជាដើម បុគ្គលនោះក៏រមែងបានបុណ្យច្ចបប្រទះសេចក្តីចំរើន បើជាមានកាយវាចាចិត្តប្រព្រឹត្តអាក្រក់ខុសចាកសីលធម៌មិនមានព្រហ្មវិហារផ្សាយទៅក្នុងពួកសត្វ មិនមានកតញ្ញូកតវេទីចំពោះលោកអ្នកមានគុណទេ ក៏រមែងបានបាប ទទួលទោសដោយខ្លួនឯងមិនចាំបាច់មាននរណាប្រគល់បុណ្យប្រគល់បាបឲ្យទេ នេះជាសេចក្តីសំដែងឲ្យឃើញថាបុណ្យបាបមិនចេះវិនាស អ្នកណាធ្វើក្នុងកាលណា អ្នកនោះត្រូវបានក្នុង កាលនោះឬកាលខាងមុខ ៗ ។ បុណ្យបាបគុណទោសទាំងនេះឯងហៅថាធម៌, មួយទៀតក្នុងគម្ពីរអដ្ឋកថាឧទានខុន្ទកនិកាយ មានសេចក្តីថាពួកធម៌ជាកុសល ហៅថាសកធម៌ គឺជាផ្លូវដ៏ពិតមួយយ៉ាងសម្រាប់នាំមកនូវសុខសួស្តី នាំមកនូវសេចក្តីចំរើន ដល់បុគ្គលអ្នកប្រព្រឹត្តសុចរិត, ពួកអកុសលហៅថាបរធម៌គឺជាផ្លូវពិតដោយឡែក សម្រាប់នាំមកនូវទុក្ខ នាំមកនូវសេចក្តីវិនាសដល់បុគ្គលអ្នកប្រព្រឹត្តទុច្ចរិត ចំណែកខាងពួកកុសលធម៌ មានសីល សមាធិ បញ្ញាជាដើមដែលធ្វើប្រយោជន៍ឲ្យដល់ខ្លួនដូចជា មាតាបិតាធ្វើប្រយោជន៍ដល់បុត្តធីតា ព្រោះហេតុនោះទើបលោកហៅថាសកធម៌, ពួកអកុសលធម៌ មានរាគៈ ទោសៈ មោហៈ ជាដើមដែលនាំបណ្តាលធ្វើប្រយោជន៍ឲ្យវិនាស ដូចជាបច្ចាមិត្ត ជាសឹកសត្រូវមកពីខាងក្រៅ មកធ្វើឲ្យខូចប្រយោជន៍ ព្រោះហេតុនោះទើបលោកហៅថាបរធម៌ ។

បុណ្យ បាប គុណទោស សកធម៌ បរធម៌ ដូចសំដែងមកនេះ ឈ្មោះថាប្រវត្តិរបស់ធម៌ ដែលជាដើមពូជចាប់កំណើតកើតឯងហើយចាក់ឫសជាប់នៅទៀងទាត់ជាធម្មតា មិនចេះចាស់គ្រាំគ្រាឬវិនាសសាបសូន្យដោយពិត តែជារបស់ស្ងាត់កំបាំងអំពីបញ្ញារបស់បុថុជ្ជន ដូចភ្លើងជារបស់មាននៅទៀងទាត់តែងចាប់កំណើតដាច់នៅនឹងអាកាស ឬនៅក្នុងដើមឈើ កាលបើគេចេះវិជ្ជាខាងគ្រឿងផ្សំ ត្រូវតាមហេតុផលល្អ ភ្លើងក៏ឆេះលះអណ្តាតឡើង បើមិនចេះគ្រឿងផ្សំទេ ភ្លើងមិនអាចឆេះឡើងបានមួយទៀតភេសជ្ជៈថ្នាំកែរោគដែលកើតអំពីជាតិឈើ ឬអំពីធាតុអ្វីផ្សេង ៗ ក៏ជារបស់ស្ថិតនៅមាននៅជាធម្មតា មិនចេះវិនាស, គ្រូពេទ្យអ្នកចេះចាំក្បួនតម្រារមែងផ្សំធាតុឬលំអិតអ្វីផ្សេង ៗ ឲ្យទៅជាភេសជ្ជៈកែរោគបានដោយងាយ ពាក្យដែលយើងធ្លាប់និយាយថា ភ្លើងរលត់ នេះជាសេចក្តីសន្មតិគឺភ្លើងគ្រាន់តែរលត់បាត់អំពីចង្កៀងប៉ុណ្ណោះ នឹងថារលត់បាត់ ទៅចាកលោកមែនទែនក៏ទេ សេចក្តីយ៉ាងណាមិញ ដំណឹងនឹងកិត្តិគុណព្រះធម៌ជាសភាពដែលពិតប្រាកដរមែងមាននៅដោយមាំមួន មិនចេះប្រែប្រួលវិនាសសាបសូន្យ មិនចេះស្លាប់ក៏យ៉ាងនោះដែរ ។ ពាក្យដែលយើងនិយាយថាព្រះធម៌សាបសូន្យ ឬថាសាសនារៀវរោយ នេះជាសម្មតិវោហារគ្រាន់តែជាពាក្យសម្រាប់ប្រើហៅបណ្តោះអាសន្ន ឬពាក្យថា សាបសូន្យរៀវរោយនោះគ្រាន់តែសំដៅយកថាព្រះធម៌សាបសូន្យចាកខន្ធសន្តានរបស់បុគ្គលអ្នកសិក្សារៀនសូត្រប្រតិបត្តិប៉ុណ្ណោះ ។ មគ្គផលនិព្វានឈ្មោះថាកិត្តិគុណរបស់ធម៌ តែងឮខ្ចរខ្ចាយនៅក្នុងលោកដោយហូរហែរជា

ដរាបមកមិនដាច់ ព្រោះហេតុនោះបុគ្គលអ្នកស៊ើបដំណឹងរកធម៌ក្នុងលោកនេះ តែងមានតែរាល់ ៗ កាល តាមសេចក្ដីប្រតិបត្តិក្នុងសាសនារបស់គេ ប៉ុន្តែច្រើនតែប្រទះទៅលើផ្លូវវាងដោយអំណាចអវិជ្ជានាំសត្វឲ្យវង្វេង ឬដោយគំនិតយល់ខុសតាមលិទ្ធិរបស់គ្រូដោយខ្លួន ៗ ។ ក្នុងកាលចន្លោះព្រះពុទ្ធត្រាស់ឡើងគង់ប្រាកដថា មានបុគ្គលខ្លះក្នុងលោកមានចិត្តនឿយណាយចាកកាមគុណ នឹកភ្នកចង់ស្វះស្វែងរកប្រវត្តិពង្សាវតារ ដែលជាក្រសែនៃមោក្ខធម៌គឺព្រះនិព្វាន ហើយលះភេទគ្រហស្ថចេញចាកកាមារម្មណ៍ កាន់ភេទជាតាបសឥសីប្រព្រឹត្តតបវត្តដើម្បីស្រូតទៅរកព្រះនិព្វានជាធម្មតា ។ តាបសខ្លះប្រទះបានតែត្រឹមឈានសមាបត្តិ ឬអភិញ្ញាជាលោកិយប៉ុណ្ណោះ តាបសខ្លះឃ្លាងរហូតដោយហេតុខ្វះគ្រឿងផ្សំ ឬមានគ្រឿងផ្សំធាតុវិជ្ជាប្រាជ្ញាស្មារតីមិនទាន់គ្រប់គ្រាន់, ព្រះសម្ពុទ្ធរបស់យើង កាលនៅជាពោធិសត្វ ក៏នៅក្នុងពួកតាបសដូច្នោះដែរ ព្រះអង្គតែងជាប់ព្រះហឫទ័យក្នុងការស្វែងរកព្រះធម៌ទោះបីព្រះអង្គបានជាក្សត្រិយ៍សោយរាជ្យ ដែលគួរស្រវឹងក្នុងសម្បត្តិនឹងយសបរិវារទ្រង់ក៏មិនភ្លេចអំពីដំណឹងបុណ្យបាប តែងពេញព្រះហឫទ័យក្នុងភេទតាបសជារឿយ ៗ ខំប្រព្រឹត្តិវត្តយ៉ាងឧក្រឹដ្ឋជាងតាបសឯទៀត ៗ ជាដរាបអស់ច្រើនជាតិណាស់ ។ ព្រះមហាបុរសមានព្យាយាមក្លៀវក្លាអន្ទោកអន្ទោលមិនតក់មិនលែងចោលអំពីការស្វែងរកមោក្ខធម៌ ព្រោះអាស្រ័យការដឹងថាមុខជានឹងបានដូចប្រាថ្នាព្រះអង្គខំប្រឹងសន្សំសេចក្ដីល្អល្អះសេចក្ដីអាក្រក់ចំណាំប្រវត្តិរបស់ព្រះអង្គនឹងព្រះធម៌ដែលព្រះអង្គធ្លាប់ប្រតិបត្តិមករៀងរាបដរាបដល់បច្ឆិមជាតិទើបបានគ្រឿងផ្សំធាតុសព្វគ្រប់ដែលហៅថាបារមីធម៌ ១០ ប្រការនោះឯង ។

លុះព្រះបរមពោធិសត្វមានបារមីធម៌ ចូលមកគ្រប់គ្រាន់ ក៏បានរំពឹងស្រាវជ្រាវរកពង្សាវតារព្រះធម៌ជាអនុលោមប្បដិលោម បានឃើញជាក់ច្បាស់ដោយសព្វញ្ញុតញ្ញាណហើយទ្រង់សំដែងបើកបង្ហើបបង្ហាញធម៌នោះ ៗ ដល់ពួកពុទ្ធបរិស័ទឲ្យភ្លឺច្បាស់ហាក់ដូចជាព្រះច័ន្ទរះឡើងក្នុងថ្ងៃ ១៥ កើត ។ ព្រះធម៌ដែលចាប់កំណើតនៅក្នុងផ្ទៃលោកធាតុជាយូរលង់មកហើយនោះស្រាប់តែផុះអណ្ដែតឡើង ហាក់ដូចជាប្រសូតចាកលោកធាតុមកប្រតិស្ឋានថ្មី ៗ ចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគ នេះឯងហៅថាព្រះអង្គត្រាស់ដឹង ។ មូលហេតុដែលនាំឲ្យពួកតាបសឯទៀត ៗ ក្ដីតាបសគឺព្រះពោធិសត្វក្ដី ខំសង្វាតបំពេញបារមីធម៌ទាំងនោះ ក៏ព្រោះអាស្រ័យការដឹងក្លិនក្រអូប ការចាំប្រវត្តិនឹងកិត្តិគុណរបស់ធម្មៈជាប់ហៃ ៗ មក ដូចដំណឹងថាមាសពេជ្រជាបច្ច័យ នាំឲ្យគេស្វែងរកមាសពេជ្រ គឺអាស្រ័យការដឹងជាដើមហេតុ ទើបមានការស្វែងរកជាខាងក្រោយ ត ៗ មករហូតបានដូចប្រាថ្នា ដំណឹងថាមគ្គផលថានិព្វានក៏រមែងមានក្លិនក្រអូបជាប់នៅក្នុងលោក សូម្បីមគ្គផលជាធម៌នាំសត្វឲ្យឆ្លងឡើងចាកលោក ព្រះនិព្វានជាគុណជាតិផុតស្រឡះចាកលោកហើយក៏ពិតមែន តែកិត្តិស័ព្ទរមែងសល់នៅក្នុងលោកមិនចេះសាបសូន្យ ។ លុះព្រះអង្គបរិបូណ៌ដោយប្រាជ្ញា

ស្មារតី គ្រប់គ្រាន់ដោយសេចក្តីត្រិះរិះជ្រាបច្បាស់ចំពោះព្រះអង្គហើយទើបទ្រង់លើកស្រង់ស្រាវជ្រាវប្រមូលយក ព្រះធម៌ដែលមាននៅក្នុងលោកស្រាប់នោះមកសំដែងសើរើចែករលែកឲ្យមានមេមាតិកាដោតក្រងតម្រៀប ដូចមានកម្រងមានរបៀបជាគោលចារឹករាក់ជ្រៅ សង្ខេបពិស្តារច្បាស់លាស់ជាក់ស្តែងឡើងដើម្បីឲ្យពួកពុទ្ធបរិស័ទនិកាយរបស់ព្រះអង្គងាយស្តាប់ងាយពិចារណារកផ្លូវប្រតិបត្តិពួកប្រជាជនអ្នកមានសេចក្តីជ្រះថ្លាក្នុងធម៌ គោរពចំពោះព្រះអង្គក៏នាំគ្នាហៅថាព្រះអង្គបានត្រាស់ ដរាបមក ។ ធម៌ដែលព្រះអង្គបានត្រាស់ដឹងទាំងនោះ ក៏គឺធម៌ដែលធ្លាប់មានស្រាប់នៅក្នុងលោកនោះឯង ។ ព្រះបរមសាស្តាចារ្យបានត្រាស់ដឹងធម៌ឡើងក្នុងលោកក្នុងកាលណាម្តង ៗ គួរហៅថាអគ្គសង្គាយនាមួយលើកហើយ ក្នុងកាលនោះរាប់ថា សង្គាយនាមុនដំបូងបង្អស់ ជាគុណដ៏ប្រសើរបំផុតធំបណ្តាច់ជាងសង្គាយនារបស់ព្រះអរហន្តទាំងឡាយ ដែលធ្វើក្នុងកាលជាខាងក្រោយ ។

ពណ៌នាមកអំពីអត្ថនឹងវិគ្គហៈ របស់ធម្មៈ

ព្រមទាំងប្រវត្តិនឹងកិត្តិគុណរបស់ធម្មៈចប់តែប៉ុណ្ណោះ ។

bymahahormmonysohan (MBA,MED.MAG)

at kampong chamcambodia